# សេចក្តីថ្លែងការណ៍

## ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០

## សវនាការឌុចៈ គំរូមួយដ៏ល្អសម្រាប់តុលាការកម្ពុជា

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (ម.ស.ម.ក) អបអរសាទរចំពោះអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អង្គជំនុំជម្រះវិសាមញ្ញ) ដែលបានចេញសាលក្រមសម្រេចសេចក្តីលើករណីកាំង ហ្កេកអ៊ាវ ហៅ "ឌុច" មេដឹកនាំជាន់ខ្ពស់ទី១ ដែលត្រូវបាននាំមក ដើម្បីស្វែងរកយុត្តិធម៌ចំពោះបទឧក្រិដ្ឋ ដែលត្រូវបានប្រព្រឹត្តនៅក្នុងអំឡុងរបបខ្មែរក្រហម។ សវនាការឌុច គឺជាឧទាហរណ៍មួយដ៏សំខាន់សម្រាប់តុលាការក្នុងស្រុកនៃប្រទេសកម្ពុជាយកគំរូតាមទាំងនីតិវិធី និងសិទ្ធិជនជាប់ចោទ។ នៅក្នុងករណីនេះមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា សូមសាទរចំពោះការកាត់បន្ថយទោសរបស់ឌុច រយៈពេល ៥ ឆ្នាំ ដោយសារការឃុំខ្លួនឌុចខុសច្បាប់នៅឯតុលាការយោធាកម្ពុជាចាប់តាំងពីថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៩៩ រហូតដល់ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៧។ ការកាត់បន្ថយទោសនេះ ជាឧទាហរណ៍មួយដ៏ល្អសម្រាប់តុលាការក្នុងស្រុកនៃប្រទេសកម្ពុជា ដែលក្នុងនោះការអនុវត្តនៃការឃុំខ្លួនបណ្តោះអាសន្ន នៅតែជាបញ្ហាធ្ងន់ធ្ងរគួរឱ្យបារម្ភ និងជាការរំឭកអំពីសិទ្ធិមនុស្សជាសកល។

ឌុចត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគាររយៈពេល ៣៥ ឆ្នាំ ពីបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋសង្គ្រាម។ ការផ្តន្ទាទោសនេះបន្ថយនៅត្រឹម ១៩ ឆ្នាំ ក្រោយពីដករយៈពេលដែលឌុចនៅក្នុងពន្ធនាគារ និងការកាត់បន្ថយទោសរយៈពេល ៥ ឆ្នាំ។ រយៈពេលនេះត្រូវបានសារព័ត៌មានញូវយ៉កថៃមស៍ លើកឡើងថា ហាក់ដូចជាត្រូវបានមនុស្សភាគច្រើនមើលឃើញថា "ជាការអត់ឱនដ៏គួរឱ្យភ្ញាក់ផ្អើល"។ តាមពិត បើគិតពីការស្លាប់របស់អ្នកទោសយ៉ាងហោចណាស់ ១២ ២៧៣ នាក់ នៅក្នុងមន្ទីរឃុំឃាំងទួលស្លែង ដោយសារស្នាដៃឌុច ការផ្តន្ទាទោសមានលក្ខណៈស្រាល។ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាមិនធ្វើការអត្ថាធិប្បាយទៅលើភាពត្រឹមត្រូវ ឬមិនត្រឹមត្រូវនៃការផ្តន្ទាទោសនេះទេ។ ប៉ុន្តែសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស បានចែងថា "គ្រប់សមាជិកទាំងអស់នៃគ្រួសារមនុស្ស" មាន "សិទ្ធិស្មើគ្នា និងមិនអាចរំលោភបាន" ដូច្នេះគឺបូករួមទាំងសមាជិកជាន់ខ្ពស់នៃរបបខ្មែរក្រហម ដែលត្រូវបានមនុស្សភាគច្រើនមើលឃើញថា មិនអាចការពារបាន។ ដោយសារមូលហេតុនេះហើយ ទើបមជ្ឈមណ្ឌលសិទ្ធិមនុស្សសាទរចំពោះការកាត់បន្ថយទោសឌុច ដែលជាលទ្ធផលនៃ "ការរំលោភសិទ្ធិ

(របស់ឌុច) នៅក្នុងខណៈដែលឌុចត្រូវបានឃុំខ្លួនខុសច្បាប់ដោយតុលាការយោធាកម្ពុជាចាប់ពីថ្ងៃទី ១០ ខែឧសភា ឆ្នាំ១៩៩៩ ដល់ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៧"។

ការកាត់បន្ថយទោសនេះ ក៏ជាឧទាហរណ៍មួយដ៏សំខាន់សម្រាប់តុលាការក្នុងស្រុកនៃប្រទេសកម្ពុជាអំពីភាពមិនអាចរំលោភបាននៃសិទ្ធិរបស់ជនជាប់ចោទ។ ក្រមនីតិវិធីព្រហ្មទណ្ឌនៃប្រទេសកម្ពុជា បានចែងអំពីសច្ចធារណ៍នៃសេរីភាព និងប្រឆាំងចំពោះការឃុំខ្លួនបណ្តោះអាសន្ននូវបុគ្គលណាដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តបទល្មើស និងរង់ចាំសវនាការ។ ប៉ុន្តែ ដូចដែលបានលើកឡើងនៅក្នុងរបាយការណ៍ប្រចាំឆមាសទាក់ទងនឹងការសង្កេតការណ៍សវនាការ ដែលទើបនឹងត្រូវបានបោះពុម្ពផ្សាយនាពេលថ្មីៗនេះ មានកង្វល់មួយចំនួនទាក់ទងនឹងការអនុវត្តការឃុំខ្លួនបណ្តោះអាសន្ននៅក្នុងប្រទេសកម្ពុជា។ ជាពិសេស កង្វល់ទាក់ទងនឹងការរកឃើញថា នៅក្នុងសវនាការចំនួន ៨៨% នៃសវនាការទាំងអស់ដែលបានសង្កេត ជនជាប់ចោទត្រូវបានឃុំខ្លួនបណ្តោះអាសន្ន។ នៅក្នុងបរិបទនេះសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបានកាត់បន្ថយទោសឌុច ដោយសារឌុចត្រូវបានឃុំខ្លួនខុសច្បាប់នោះ គឺជារឿងមួយដែលត្រូវអបអរសាទរ។

លោក អ៊ូ វីរៈ ប្រធានមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ដែលជាជនរងគ្រោះម្នាក់នៃរបបខ្មែរក្រហម មានប្រតិកម្មទៅនឹងសាលក្រម និងការផ្តន្ទាទោស ដូចតទៅ៖ "ជាការលំបាកសម្រាប់ជនរងគ្រោះ និងអ្នកសង្កេត មួយចំនួន ក្នុងការផ្សះផ្សាការរកឃើញរបស់តុលាការជាមួយនឹងការផ្តន្ទាទោសដែលបានសម្រេច។ ប៉ុន្តែ បញ្ហាទាក់ទងនឹងការអនុវត្តនៃការឃុំខ្លួនបណ្តោះអាសន្នដែលកើតមានឡើងក្នុងប្រទេសកម្ពុជា និងការកាត់បន្ថយទោស ដោយសារការឃុំខ្លួនឌុចដោយខុសច្បាប់កាលពីមុន គឺជាឧទាហរណ៍មួយដ៏ល្អ សម្រាប់តុលាការក្នុងស្រុករបស់យើង។ ខ្ញុំគិតថា ជាបញ្ហាសំខាន់ផងដែរ ការណ៍ដែលសាលក្រមនេះបាននាំមកប្រទេសកម្ពុជានូវសិទ្ធិមនុស្សជាសកល និងការណ៍ដែលសិទ្ធិគឺសម្រាប់ជនគ្រប់រូបទាំងអស់ រួមទាំងបុគ្គលទាំងឡាយណាដែលត្រូវបានមនុស្សភាគច្រើនមើលឃើញថា អាក្រក់មិនអាចទទួលយកបាន។

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖**

លោក អ៊ូ វីរៈ ប្រធានមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
លេខទូរស័ព្ទ ៖ (៨៥៥) ១២ ៤០ ៤០ ៥១
អ៊ីមែល ៖ ouvirak@cchrcambodia.org

ប្រសិនបើអ្នកចង់អានរបាយការណ៍ប្រចាំឆមាសនៃគម្រោងសង្កេតការណ៍សវនាការរបស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា "សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅកម្ពុជា" សូមទស្សនាគេហទំព័រស្តីពីសិទ្ធិមនុស្សកម្ពុជា www.sithi.org ។